# កិច្ចព្រមព្រៀងទីក្រុងប៉ារីស

# កិច្ចព្រមព្រៀងទីក្រុងប៉ារីស

***បណ្ដាភាគីក្នុងកិច្ចព្រមព្រៀងនេះ***

*ក្នុងនាម*ភាគីនៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ ដែលចាប់ពីនេះទៅហៅថា"អនុសញ្ញានេះ"

*អនុលោមតាម* វេទិកាទីក្រុងឌូបានសម្រាប់ការពង្រឹងសកម្មភាព ដែលបានបង្កើតឡើងដោយសេចក្ដីសម្រេច1/CP.17នៃសន្និសីទបណ្ដាភាគីក្នុងអនុសញ្ញានេះនាសម័យប្រជុំលើកទីដប់ប្រាំពីររបស់ខ្លួន

*នៅក្នុងការជំរុញ* គោលបំណងអនុសញ្ញានេះ និងស្របតាមគោលការណ៍នៃអនុសញ្ញានេះ ដែលរួមបញ្ចូលទាំងគោលការណ៍សមធម៌ និងការទទួលខុសត្រូវរួម តែក្នុងកម្រិតផ្សេងគ្នា អាស្រ័យលើសមត្ថភាព និងកាលៈទេសៈរបស់ប្រទេសរៀងៗខ្លួន

*ដោយទទួលស្គាល់* ភាពចាំបាច់ឱ្យមានការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងវឌ្ឍនភាពទៅនឹងការគំរាមកំហែងបន្ទាន់ពីការប្រែប្រួលអាកាសធាតុ ដោយផ្អែកលើមូលដ្ឋាននៃចំណេះដឹងវិទ្យាសាស្ត្រថ្មីៗបំផុតដែលមាន

*ដោយទទួលស្គាល់ផងដែរ* នូវតម្រូវការជាក់លាក់ និងកាលៈទេសៈពិសេសរបស់បណ្ដាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសបណ្ដាប្រទេសដែលងាយរងគ្រោះនៅចំពោះមុខផលប៉ះពាល់ធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ ដូចមានចែងក្នុងអនុសញ្ញានេះ

*ដោយពិចារណាពេញលេញ* លើតម្រូវការជាក់លាក់ និងស្ថានភាពពិសេសរបស់បណ្ដាប្រទេសអភិវឌ្ឍន៍តិចតួច ដែលទាក់ទងនឹងការផ្ដល់មូលនិធិ និងការផ្ទេរបច្ចេកវិទ្យា

*ដោយទទួលស្គាល់* បណ្ដាភាគីអាចទទួលរងនូវផលប៉ះពាល់ មិនត្រឹមតែដោយសារការប្រែប្រួលអាកាសធាតុប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោយសារផលប៉ះពាល់នៃការបាត់វិធានការនៅក្នុងការឆ្លើយតបផងដែរ

*ដោយសង្កត់ធ្ងន់* លើទំនាក់ទំនងសំខាន់ៗដែលកើតមានរវាងផលប៉ះពាល់ ការឆ្លើយតប និងសកម្មភាពការប្រែប្រួលអាកាសធាតុ ជាមួយការទទួលបាននូវសមធម៌ក្នុងការអភិវឌ្ឍដោយចីរភាព និងការលុបបំបាត់ភាពក្រីក្រ

*ដោយទទួលស្គាល់* អាទិភាពជាមូលដ្ឋាននៃការធានាសន្តិសុខស្បៀង និងការបញ្ចប់ភាពអត់ឃ្លាន ហើយជាពិសេសភាពងាយរងគ្រោះនៃប្រព័ន្ធផលិតកម្មស្បៀងនៅចំពោះមុខផលប៉ះពាល់ធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ

*ដោយពិចារណាពី* កត្តាចាំបាច់នៃកម្លាំងពលកម្មអន្តរកាលសមស្រប និងការបង្កើតការងារសមរម្យ ព្រមទាំងការងារប្រកបដោយគុណភាព ស្របតាមអាទិភាពអភិវឌ្ឍន៍ជាតិ

*ដោយទទួលស្គាល់* ការប្រែប្រួលអាកាសធាតុគឺជាក្ដីកង្វល់រួមមួយរបស់មនុស្សជាតិ ដែលនៅពេលចាត់វិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ បណ្ដាភាគីគួរតែគោរព ជំរុញ និងគិតគូរអំពីកាតព្វកិច្ចរៀងៗខ្លួនចំពោះសិទ្ធិមនុស្ស សិទ្ធិទទួលបានសេវាសុខភាព សិទ្ធិរបស់ជនជាតិដើមភាគតិច សហគមន៍មូលដ្ឋាន ជនចំណាកស្រុក កុមារ ជនពិការ និងប្រជាជនដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ និងសិទ្ធិទទួលបានការអភិវឌ្ឍ ក៏ដូចជា សមភាពយេនឌ័រ សិទ្ធិអំណាចរបស់ស្ត្រី និងសមធម៌រវាងជំនាន់មនុស្ស

*ដោយទទួលស្គាល់* សារៈសំខាន់នៃការអភិរក្ស និងការបង្កើនអាងស្រូប និងអាងស្តុកឧស្ម័នផ្ទះកញ្ចក់ ទៅតាមករណីសមស្រប ដូចមានយោងក្នុងអនុសញ្ញានេះ

*ដោយកត់សម្គាល់* ពីសារៈសំខាន់នៃការធានាបូរណភាពប្រព័ន្ធអេកូឡូស៊ីទាំងអស់ រួមទាំង មហាសមុទ្រ និងកិច្ចការពារជីវៈចម្រុះ ដែលត្រូវបានទទួលស្គាល់ដោយវប្បធម៌មួយចំនួនថាជា *មាតាពិភពលោក* និងការកត់សម្គាល់ពីសារៈសំខាន់នៃទស្សនទានមួយចំនួនស្ដីពី "យុត្តិធម៌អាកាសធាតុ" នៅពេលចាត់វិធានការដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ

*ដោយអះអាង* ពីសារៈសំខាន់នៃការអប់រំ ការបណ្ដុះបណ្ដាល ការយល់ដឹងសាធារណៈ ការចូលរួមជាសាធារណៈ ការទទួលបាន

ព័ត៌មាន និងកិច្ចសហប្រតិបត្តិការពីសាធារណជនគ្រប់លំដាប់ថ្នាក់លើកិច្ចការនានាដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ

*ដោយទទួលស្គាល់* ពីសារៈសំខាន់នៃការចូលរួមរបស់រដ្ឋាភិបាលនៅគ្រប់លំដាប់ថ្នាក់ និងភ្នាក់ងារនានា អនុលោមតាម ច្បាប់ជាតិរបស់ភាគីនីមួយៗ នៅក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ

*ដោយទទួលស្គាល់ផងដែរ* ថារបៀបរស់នៅប្រកបដោយនិរន្តរភាពព្រមទាំងគំរូនៃផលិតកម្មនិងការប្រើប្រាស់ប្រកបដោយចីរភាព ដែលមានបណ្តាភាគីប្រទេសអភិវឌ្ឍន៍កំពុងឈានមុខ ត្រូវដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ

***បានឯកភាពគ្នាដូចតទៅ៖***

## មាត្រា១

សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ និយមន័យដូចមានចែងក្នុងមាត្រា១ នៃអនុសញ្ញានេះ នឹងត្រូវយកមកអនុវត្ត។ លើសពីនេះ៖

(ក) "អនុសញ្ញា" មានន័យថា អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលបានអនុម័តនៅទីក្រុងញ៉ូវយ៉ក កាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៩២

(ខ) "សន្និសីទបណ្តាភាគី" មានន័យថា សន្និសីទនៃបណ្តាភាគីក្នុងអនុសញ្ញានេះ

(គ) "ភាគី" មានន័យថា ភាគីណាមួយក្នុងកិច្ចព្រមព្រៀងនេះ

## មាត្រា២

១. នៅក្នុងការពង្រឹងការអនុវត្តអនុសញ្ញានេះរួមទាំងគោលដៅរបស់វា កិច្ចព្រមព្រៀងនេះមានគោលបំណងពង្រឹងការឆ្លើយតបជាសកលទៅនឹងការគំរាមកំហែងនៃការប្រែប្រួលអាកាសធាតុ នៅក្នុងបរិបទនៃការអភិវឌ្ឍដោយចីរភាព និងកិច្ចខិតខំប្រឹងប្រែងដើម្បីលុបបំបាត់ភាពក្រីក្រ ដែលរួមមាន៖

(ក) ការកំហិតកំណើនសីតុណ្ហភាពមធ្យមលើពិភពលោកឱ្យនៅត្រឹមក្រោម២°C ខ្ពស់ជាងកម្រិតសីតុណ្ហភាពនៅមុនបដិវត្តន៍ឧស្សាហកម្ម និងការជំរុញកិច្ចប្រឹងប្រែងដើម្បីកំហិតកំណើនសីតុណ្ហភាពឱ្យនៅត្រឹម១,៥°C ខ្ពស់ជាងកម្រិតសីតុណ្ហភាពនៅមុនបដិវត្តន៍ឧស្សាហកម្ម ដោយទទួលស្គាល់ថា ការធ្វើបែបនេះអាចកាត់បន្ថយយ៉ាងច្រើននូវហានិភ័យ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ

(ខ) ការបង្កើនសមត្ថភាពដើម្បីបន្សាំទៅនឹងផលប៉ះពាល់ធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ និងពង្រឹងភាពធន់នឹងអាកាសធាតុ និងការអភិវឌ្ឍដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់កម្រិតទាប តាមវិធីដែលមិនបង្កការគំរាមកំហែងចំពោះផលិតកម្មស្បៀង

(គ) ការធ្វើឱ្យលំហូរហិរញ្ញវត្ថុមានសង្គតិភាពជាមួយមាគ៌ាឆ្ពោះទៅរកការបញ្ចេញឧស្ម័នផ្ទះកញ្ចក់កម្រិតទាប និងការអភិវឌ្ឍដែលធន់នឹងអាកាសធាតុ

២. កិច្ចព្រមព្រៀងនេះនឹងត្រូវអនុវត្ត ដើម្បីឆ្លុះបញ្ចាំងសមធម៌ និងគោលការណ៍រួម តែនៅកម្រិតនៃការទទួលខុសត្រូវផ្សេងៗគ្នា និងសមត្ថភាពរៀងៗខ្លួន ដោយគិតគូរផងដែរអំពីកាលៈទេសៈខុសៗគ្នារបស់ប្រទេស។

## មាត្រា៣

ដូចមានចែងនៅក្នុងការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិ សម្រាប់ការឆ្លើយតបជាសកលទៅនឹងការប្រែប្រួលអាកាសធាតុ ភាគីទាំងអស់ត្រូវអនុវត្ត និងរាយការណ៍អំពីកិច្ចប្រឹងប្រែងប្រកបដោយមហិច្ឆតា ដូចមានចែងក្នុងមាត្រា៤, ៧, ៩, ១០, ១១ និង ១៣ ដើម្បីសម្រេចឱ្យបាននូវគោលបំណងនៃកិច្ចព្រមព្រៀងនេះ ដូចមានចែងក្នុងមាត្រា២។ កិច្ចប្រឹងប្រែងរបស់បណ្តាភាគីទាំងអស់ ត្រូវឆ្លុះបញ្ចាំងពីការរីកចម្រើនជាបន្តបន្ទាប់ ទន្ទឹមនឹងការទទួលស្គាល់នូវតម្រូវការចាំបាច់ដើម្បីគាំទ្រដល់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះដោយប្រសិទ្ធភាព។

## មាត្រា៤

១. ដើម្បីសម្រេចបានគោលបំណងសីតុណ្ហភាពរយៈពេលវែង ដូចមានចែងក្នុងមាត្រា២ ភាគីនានាមានបំណងឈានឱ្យដល់កម្រិតខ្ពស់បំផុតជាសកលនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ឱ្យបានឆាប់បំផុតតាមតែអាចធ្វើទៅបាន ដោយទទួលស្គាល់ថា សម្រាប់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ការឈានដល់កម្រិតកំពូលបែបនេះនឹងត្រូវទាមទាររយៈពេលវែងជាង និងត្រូវកាត់បន្ថយឱ្យបានឆាប់រហ័សនូវការបញ្ចេញបាប់ពីដំណាក់កាលនោះតទៅ ដោយអនុលោមតាមវិទ្យាសាស្ត្រថ្មីៗបំផុតដែលមាន ដើម្បីអាចសម្រេចបានតុល្យភាពមួយរវាងការបញ្ចេញដោយសារសកម្មភាពមនុស្ស ដោយគិតតាមប្រភព និងអាងស្រូបឧស្ម័នផ្ទះកញ្ចក់ នៅក្នុងពាក់កណ្តាលទី២នៃសតវត្សរ៍នេះ ដោយផ្អែកលើសមធម៌ និងនៅក្នុងបរិបទនៃការអភិវឌ្ឍដោយចីរភាព និងកិច្ចខិតខំប្រឹងប្រែងដើម្បីលុបបំបាត់ភាពក្រីក្រ។

២. ភាគីនីមួយៗត្រូវរៀបចំ ជូនដំណឹង និងរក្សាទុកបរិមាណនៃការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិជាបន្តបន្ទាប់ ដែលគ្រោងសម្រេចឱ្យបាន។ ភាគីនានាត្រូវចាត់វិធានការកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេស ក្នុងគោលបំណងសម្រេចគោលដៅនៃការរួមចំណែកទាំងនោះ។

៣. ការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិរបស់ភាគីនីមួយៗ នឹងតំណាងឱ្យការរីកចម្រើនជាបន្តបន្ទាប់ និងនៅកម្រិតខ្ពស់ជាងកម្រិតការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិលើកមុនៗរបស់ខ្លួន ព្រមទាំងត្រូវឆ្លុះបញ្ចាំងមហិច្ឆតាខ្ពស់បំផុតដែលខ្លួនអាចសម្រេចបានដែលបញ្ជាក់ពីការទទួលខុសត្រូវរួម តែក្នុងកម្រិតខុសៗគ្នា និងទៅតាមសមត្ថភាពរៀងៗខ្លួន ដោយគិតពីកាលៈទេសៈខុសៗគ្នារបស់ប្រទេសនីមួយៗ។

៤. បណ្តាភាគីប្រទេសអភិវឌ្ឍន៍ ត្រូវបន្តឈានមុខ ដោយអនុវត្តចំណុចដៅកាត់បន្ថយការបញ្ចេញដាច់ខាតនៅគ្រប់ផ្នែកសេដ្ឋកិច្ច។ បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ គួរបន្តពង្រឹងកិច្ចប្រឹងប្រែងកាត់បន្ថយការបញ្ចេញរបស់ខ្លួន និងត្រូវបានលើកទឹកចិត្តឱ្យឈានជាបន្តបន្ទាប់ឆ្ពោះទៅសម្រេចចំណុចដៅកាត់បន្ថយឬកម្រិតលើការបញ្ចេញនៅគ្រប់ផ្នែកសេដ្ឋកិច្ច ដោយគិតគូរផងដែរពីកាលៈទេសៈខុសៗគ្នារបស់ប្រទេសនីមួយៗ។

៥. ការគាំទ្រគួរតែបានផ្តល់ឱ្យបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ សម្រាប់ការអនុវត្តមាត្រានេះ ដោយអនុលោមតាមមាត្រា៩, ១០ និង ១១ ដោយទទួលស្គាល់ថា ការពង្រឹងកិច្ចគាំទ្រដល់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍នឹងអាចជួយធ្វើឱ្យមហិច្ឆតានៃសកម្មភាពរបស់បណ្តាភាគីប្រទេសទាំងនោះស្ថិតនៅកម្រិតខ្ពស់ជាងមុន។

៦. បណ្តាប្រទេសអភិវឌ្ឍន៍តិចតួច និងបណ្តារដ្ឋកូនកោះកំពុងអភិវឌ្ឍន៍អាចរៀបចំ និងផ្សព្វផ្សាយយុទ្ធសាស្ត្រ ផែនការ និងសកម្មភាពនានាសម្រាប់ការអភិវឌ្ឍដោយបញ្ចេញឧស្ម័នផ្ទះកញ្ចក់កម្រិតទាប ដែលឆ្លុះបញ្ចាំងពីកាលៈទេសៈពិសេសរបស់ខ្លួន។

៧. សហអត្ថប្រយោជន៍នៃការកាត់បន្ថយដែលកើតចេញពីសកម្មភាពបន្សាំ និង/ឬផែនការពិពិធកម្មសេដ្ឋកិច្ចរបស់បណ្តាភាគី អាចរួមចំណែកទៅក្នុងលទ្ធផលនៃការកាត់បន្ថយដូចមានចែងក្នុងមាត្រានេះ។

៨. នៅក្នុងការធ្វើរបាយការណ៍អំពីការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិរបស់ខ្លួន ភាគីទាំងអស់ត្រូវផ្តល់ព័ត៌មានចាំបាច់សម្រាប់ភាពច្បាស់លាស់ តម្លាភាពនិងការយល់ដឹង អនុលោមតាមសេចក្តីសម្រេច 1/CP.21 និងសេចក្តីសម្រេចពាក់ព័ន្ធនានានៃសន្និសីទបណ្តាភាគីដែលមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

៩. ភាគីនីមួយៗត្រូវធ្វើរបាយការណ៍អំពីការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិរៀងរាល់ប្រាំឆ្នាំម្តង អនុលោមតាមសេចក្តីសម្រេច 1/CP.21 និងសេចក្តីសម្រេចពាក់ព័ន្ធនានានៃសន្និសីទបណ្តាភាគីដែលមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ហើយត្រូវបានទទួលព័ត៌មានតាមរយៈលទ្ធផលនៃរបាយការណ៍សំយោគជាសកល ដូចមានចែងក្នុងមាត្រា១៤។

១០. នៅក្នុងសម័យប្រជុំលើកទីមួយរបស់ខ្លួន សន្និសីទបណ្តាភាគីដែលមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវពិចារណាអំពីក្របខណ្ឌពេលវេលារួម សម្រាប់ការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិ។

១១. ភាគីមួយ អាចធ្វើការកែសម្រួលការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិដែលមានស្រាប់របស់ខ្លួនគ្រប់ពេលវេលា ក្នុងបំណងបង្កើនកម្រិតមហិច្ឆតារបស់ខ្លួន ស្របតាមសេចក្តីណែនាំដែលបានអនុម័តដោយសន្និសីទបណ្តាភាគីដែលមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

១២. ការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិដែលបណ្តាភាគីបានរាយការណ៍ ត្រូវតែបានកត់ត្រាទុកនៅក្នុងបញ្ជីសាធារណៈមួយដែល

រក្សាទុកដោយលេខាធិការដ្ឋាន។

១៣. បណ្តាភាគីត្រូវកត់ត្រាការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិរបស់ខ្លួន។ នៅក្នុងការគណនាការស្រូប និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយសកម្មភាពមនុស្ស ដែលត្រូវគ្នានឹងបោយការណ៍រួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិរបស់ខ្លួន បណ្តាភាគីត្រូវលើកកម្ពស់បូរណភាពបរិស្ថាន តម្លាភាព សុក្រិតភាព ភាពពេញលេញ ភាពអាចប្រៀបធៀបបាន និងសង្គតិភាព ហើយត្រូវបញ្ចៀសការគណនាទ្វេដង ដោយគោរពតាមសេចក្តីណែនាំដែលបានអនុម័តដោយសន្និសីទបណ្តាភាគីដែលមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

១៤. នៅក្នុងបរិបទនៃការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិ នៅពេលមានការទទួលស្គាល់ និងការអនុវត្តសកម្មភាពកាត់បន្ថយ ដែលទាក់ទងនឹងការស្រូប និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយសកម្មភាពមនុស្ស បណ្តាភាគីត្រូវយកចិត្តទុកដាក់ចំពោះវិធីសាស្ត្រ និងការណែនាំដែលមានស្រាប់នានានៅក្រោមអនុសញ្ញានេះ ទៅតាមករណីសមស្រប ដោយយោងតាមប្រការនានាដែលមានចែងក្នុងកថាខណ្ឌ១៣ នៃមាត្រានេះ។

១៥. នៅក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ បណ្តាភាគីត្រូវយកចិត្តទុកដាក់ចំពោះកង្វល់របស់បណ្តាភាគីដែលមានសេដ្ឋកិច្ចរងផលប៉ះពាល់ខ្លាំងបំផុតដោយសារឥទ្ធិពលនៃវិធានការឆ្លើយតប ជាពិសេស បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍។

១៦. បណ្តាភាគី រួមទាំងអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងរដ្ឋជាសមាជិកនៃអង្គការនោះ ដែលបានឈានដល់កិច្ចព្រមព្រៀងធ្វើសកម្មភាពរួមគ្នា ដូចមាននៅក្នុងកថាខណ្ឌ២ នៃមាត្រានេះ ត្រូវជូនដំណឹងទៅកាន់លេខាធិការដ្ឋានអំពីលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនោះ រួមទាំងកម្រិតបញ្ចេញ ដែលបានកំណត់ សម្រាប់ភាគីនីមួយៗនៅក្នុងអំឡុងពេលពាក់ព័ន្ធ នៅពេលដែលភាគីទាំងនោះធ្វើរបាយការណ៍រួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិរបស់ខ្លួន។ លេខាធិការដ្ឋានត្រូវជូនដំណឹងដល់បណ្តាភាគី និងហត្ថលេខីនៃអនុសញ្ញានេះ អំពីលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនោះ។

១៧. ភាគីនីមួយៗនៅក្នុងកិច្ចព្រមព្រៀងណាមួយ ត្រូវមានទំនួលខុសត្រូវលើកម្រិតនៃការបញ្ចេញរបស់ខ្លួន ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ដោយយោងតាមកថាខណ្ឌ១៦ ខាងលើ អនុលោមតាមកថាខណ្ឌ១៣ និង ១៤ នៃមាត្រានេះ ព្រមទាំងមាត្រា១៣ និង ១៥។

១៨. ប្រសិនបើភាគីដែលធ្វើសកម្មភាពរួមគ្នានៅក្នុងក្របខណ្ឌ នៃអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ជាមួយគ្នា ដែល ជាភាគីមួយនៃកិច្ចព្រមព្រៀងនេះ រដ្ឋជាសមាជិកនីមួយៗរៀងខ្លួននៃអង្គការសមាហរកម្មសេដ្ឋកិច្ចតំបន់ និងជាមួយអង្គការសមាហរកម្មសេដ្ឋកិច្ចតំបន់ ត្រូវមានការទទួលខុសត្រូវលើកម្រិតនៃការបញ្ចេញរបស់ខ្លួន ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងដែលនៅក្នុងរបាយការណ៍ក្រោមកថាខណ្ឌ១៦ នៃមាត្រានេះ អនុលោមតាមកថាខណ្ឌ១៣ និង ១៤ នៃមាត្រានេះ និងមាត្រា១៣ និង ១៥។

១៩. ភាគីទាំងអស់គួរប្រឹងប្រែងរៀបចំ និងធ្វើរបាយការណ៍ពីយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ទាបសម្រាប់រយៈពេលវែង ដោយត្រូវគិតដល់មាត្រា២ និងត្រូវពិចារណាអំពីការទទួលខុសត្រូវរួម តែក្នុងកម្រិតខុសៗគ្នា និងទៅតាមសមត្ថភាពរៀងៗខ្លួន ដោយគិតពីកាលៈទេសៈខុសៗគ្នារបស់ប្រទេសនីមួយៗ។

## មាត្រា៥

១. បណ្តាភាគីគួរចាត់វិធានការដើម្បីអភិរក្ស និងបង្កើនអាងស្រូប និងអាងស្តុកឧស្ម័នផ្ទះកញ្ចក់ ទៅតាមករណីសមស្រប ដូចមានយោងក្នុងមាត្រា៤ កថាខណ្ឌ១ (ឃ) នៃអនុសញ្ញានេះ ដែលរួមទាំងព្រៃឈើផងដែរ។

២. បណ្តាភាគីត្រូវបានលើកទឹកចិត្តឱ្យចាត់វិធានការអនុវត្ត និងគាំទ្រ ដោយរួមទាំងតាមរយៈ ការបង់ថ្លៃផ្អែកតាមលទ្ធផល ក្របខណ្ឌដែលមានស្រាប់ដូចចែងនៅក្នុងសេចក្តីណែនាំពាក់ព័ន្ធ និងសេចក្តីសម្រេច ដែលបានឯកភាពគ្នារួចហើយនៅក្រោមអនុសញ្ញានេះ សម្រាប់៖ អភិក្រមគោលនយោបាយ និងការលើកទឹកចិត្តវិជ្ជមានសម្រាប់សកម្មភាពនានាពាក់ព័ន្ធនឹងការកាត់បន្ថយការបញ្ចេញពីការបាត់បង់និងរេចរឹលព្រៃឈើ ព្រមទាំងតួនាទីនៃការអភិរក្ស ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និងការបង្កើនអាងស្តុកកាបូនព្រៃឈើនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍, និងអភិក្រមគោលនយោបាយជំនួស ដូចជាអភិក្រមរួមនៃការកាត់បន្ថយ និងបន្សាំសម្រាប់គ្រប់គ្រងព្រៃឈើទាំងមូលនិងដោយមាននិរន្តរភាព ទន្ទឹមនឹងការអះអាងឡើងវិញពីសារៈសំខាន់នៃការផ្តល់ការលើកទឹកចិត្ត ទៅតាមករណីសមស្រប សម្រាប់អត្ថប្រយោជន៍មិនមែនកាបូន ដែលពាក់ព័ន្ធនឹងអភិក្រមបែបនេះ។

## មាត្រា៦

១. បណ្តាភាគីទទួលស្គាល់ថា ភាគីមួយចំនួនជ្រើសយកបន្តកិច្ចសហប្រតិបត្តិការដោយស្ម័គ្រចិត្តនៅក្នុងការអនុវត្តការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិរបស់ខ្លួន ដើម្បីអាចឱ្យមានមហិច្ឆតាកម្រិតខ្ពស់ជាងមុននៅក្នុងសកម្មភាពកាត់បន្ថយ និងបន្សាំរបស់ខ្លួន និងដើម្បីលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព និងបូរណភាពបរិស្ថាន។

២. ក្នុងករណីការចូលរួមដោយស្ម័គ្រចិត្តនៅក្នុងអភិក្រមបែបសហប្រតិបត្តិការពាក់ព័ន្ធទៅនឹងការប្រើប្រាស់លទ្ធផលនៃការកាត់បន្ថយដែលអាចផ្ទេរបានជាអន្តរជាតិ ឆ្ពោះទៅរកការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិ បណ្តាភាគីត្រូវជំរុញការអភិវឌ្ឍដោយចីរភាព និងធានាបូរណភាពនិងតម្លាភាពបរិស្ថាន រួមទាំងអភិបាលកិច្ច និងត្រូវប្រើប្រាស់ការគណនាដែលច្បាស់លាស់ ក្នុងចំណោមបញ្ហាទាំងនោះដើម្បីបញ្ចៀសការគណនាទ្វេដង និងដើម្បីឱ្យមានសង្គតិភាពជាមួយសេចក្តីណែនាំដែលបានអនុម័តដោយសន្និសីទបណ្តាភាគីដែលមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

៣. ការប្រើប្រាស់លទ្ធផលនៃការកាត់បន្ថយដែលអាចផ្ទេរបានជាអន្តរជាតិ ដើម្បីសម្រេចបានការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិនៅក្រោមកិច្ចព្រមព្រៀងនេះ ត្រូវតែជាការស្ម័គ្រចិត្ត និងការអនុញ្ញាតដោយបណ្តាភាគីដែលចូលរួម។

៤. យន្តការមួយដើម្បីរួមចំណែកក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព ត្រូវបង្កើតឡើងនៅក្រោមសមត្ថកិច្ច និងការណែនាំនៃសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ សម្រាប់ប្រើប្រាស់ដោយបណ្តាភាគីតាមការស្ម័គ្រចិត្ត។ ការប្រើប្រាស់បែបនេះគួរតែស្ថិតក្រោមការណែនាំរបស់អង្គដែលបានតែងតាំងដោយសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំរបស់ភាគីក្នុងកិច្ចព្រមព្រៀងក្រុងប៉ារីស និងត្រូវមានបំណង ដើម្បី៖

(ក) ជំរុញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ទន្ទឹមនឹងការពង្រឹងការអភិវឌ្ឍដោយចីរភាព

(ខ) ផ្តល់ការលើកទឹកចិត្ត និងសម្រួលដល់ការចូលរួមនៅក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយអង្គភាពសាធារណៈ និងឯកជន ដោយមានការអនុញ្ញាតពីភាគីណាមួយ

(គ) រួមចំណែកក្នុងការកាត់បន្ថយនៃកម្រិតបញ្ចេញឧស្ម័ននៅក្នុងភាគីជាម្ចាស់ផ្ទះ ដែលនឹងទទួលអត្ថប្រយោជន៍ពីសកម្មភាពកាត់បន្ថយចេញពីការកាត់បន្ថយឧស្ម័ន ដែលក៏អាចប្រើប្រាស់ដោយភាគីដទៃទៀត ដើម្បីបំពេញការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិរបស់ភាគីនោះផងដែរ និង

(ឃ) ផ្តល់នូវការកាត់បន្ថយជារួមក្នុងការបញ្ចេញឧស្ម័នជាសកល។

៥. ការកាត់បន្ថយការបញ្ចេញឧស្ម័នចេញពីយន្តការយោងទៅក្នុងកថាខណ្ឌ៤ នៃមាត្រានេះ នឹងមិនត្រូវប្រើប្រាស់ដើម្បីបង្ហាញពីសមិទ្ធផលការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិរបស់ភាគីជាម្ចាស់ផ្ទះឡើយ ប្រសិនបើត្រូវប្រើប្រាស់ដោយភាគីដទៃដើម្បីបង្ហាញពីសមិទ្ធផលនៃការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិរបស់ខ្លួន។

៦. សន្និសីទបណ្តាភាគីដែលមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវធានាថាភាគចំណែកមួយនៃផលចំណូលពីសកម្មភាពនានានៅក្រោមយន្តការយោងទៅក្នុងកថាខណ្ឌ៤ នៃមាត្រានេះ នឹងត្រូវប្រើប្រាស់សម្រាប់បំពេញការចំណាយរដ្ឋបាល ក៏ដូចជាដើម្បីជួយបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសងាយរងគ្រោះនៅចំពោះមុខផលប៉ះពាល់ធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុដើម្បីបំពេញការចំណាយបន្សាំផងដែរ។

៧. សន្និសីទបណ្តាភាគីដែលមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវអនុម័តបទបញ្ជា បែបបទ និងនីតិវិធីសម្រាប់យន្តការយោងទៅក្នុងកថាខណ្ឌ ៤ នៃមាត្រានេះ នាសម័យប្រជុំលើកទីមួយរបស់ខ្លួន។

៨. បណ្តាភាគីទទួលស្គាល់សារៈសំខាន់នៃអភិក្រមមិនមែនទីផ្សារមានគុណភាព លក្ខណៈចម្រុះ និងគ្រប់ជ្រុងជ្រោយ ដែលបណ្តាភាគីអាចយកទៅប្រើប្រាស់បាន ដើម្បីជួយនៅក្នុងការអនុវត្តការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិរបស់ខ្លួន នៅក្នុងបរិបទនៃការអភិវឌ្ឍដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ តាមទម្រង់ដែលមានការសម្របសម្រួល និងប្រកបដោយប្រសិទ្ធភាព ដែលរួមទាំង តាមរយៈការកាត់បន្ថយ ការបន្សាំ ហិរញ្ញវត្ថុ ការផ្ទេរបច្ចេកវិទ្យា និងការកសាងសមត្ថភាព ទៅតាមករណីសមស្រប។ អភិក្រមទាំងនេះត្រូវមានបំណងដើម្បី៖

(ក) លើកកម្ពស់មហិច្ឆតានៃការកាត់បន្ថយ និងបន្សាំ

(ខ) ពង្រឹងការចូលរួមពីវិស័យសាធារណៈ និងឯកជននៅក្នុងការអនុវត្តការចូលរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិ និង

(គ) ជំរុញកាលានុវត្តភាពសម្រាប់ការសម្របសម្រួលរវាងបរិធាននានា និងការចាត់ចែងស្ថាប័នពាក់ព័ន្ធ។

៩. ក្របខណ្ឌមួយសម្រាប់អភិក្រមមិនមែនទីផ្សារដើម្បីការអភិវឌ្ឍដោយចីរភាព ត្រូវបានបញ្ជាក់នៅទីនេះ ដើម្បីលើកកម្ពស់អភិក្រមមិនមែនទីផ្សារ ដូចមានយោងទៅក្នុងកថាខណ្ឌ៨ នៃមាត្រានេះ។

## មាត្រា៧

១. តាមរយៈនេះ បណ្តាភាគីបង្កើតគោលបំណងជាសកលស្តីពីបន្សុំនៃការលើកកម្ពស់សមត្ថភាពបន្សុំ ពង្រឹងភាពធន់ និងកាត់បន្ថយភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងទស្សនៈរួមចំណែកទៅក្នុងការអភិវឌ្ឍដោយចីរភាព និងការធានាឱ្យបានគ្រប់គ្រាន់លើការឆ្លើយតបទៅនឹងបន្សុំ នៅក្នុងបរិបទនៃគោលបំណងសីតុណ្ហភាពដូចមានចែងក្នុងមាត្រា ២។

២. បណ្តាភាគីទទួលស្គាល់ថា បន្សុំ គឺជាការប្រឈមសកលមួយសម្រាប់គ្រប់លំដាប់ថ្នាក់ ទាំងនៅថ្នាក់មូលដ្ឋាន ថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ហើយនេះជាសមាសភាគគន្លឹះមួយនិងជាការចូលរួមចំណែកក្នុងការឆ្លើយតបជាសកលរយៈពេលវែងទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីការពារប្រជាជន ជីវភាពរស់នៅ និងប្រព័ន្ធអេកូឡូស៊ី ដោយគិតគូរផងដែរអំពីតម្រូវការបន្ទាន់ និងចំពោះមុខរបស់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ដែលងាយរងគ្រោះ ជាពិសេសទៅនឹងផលប៉ះពាល់ធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ។

៣. កិច្ចប្រឹងប្រែងបន្សុំរបស់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវបានទទួលស្គាល់ស្របតាមបែបបទដែលបានអនុម័តដោយសន្និសីទបណ្តាភាគីដែលមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ នាសម័យប្រជុំលើកទីមួយរបស់ខ្លួន។

៤. បណ្តាភាគីទទួលស្គាល់ថា តម្រូវការបច្ចុប្បន្នសម្រាប់បន្សុំមានសារៈសំខាន់ណាស់ ហើយកម្រិតនៃការកាត់បន្ថយកាន់តែច្រើន អាចបន្ថយនូវតម្រូវការសម្រាប់កិច្ចប្រឹងប្រែងបន្សុំបន្ថែមទៀត ហើយតម្រូវការបន្សុំកាន់តែច្រើន អាចទាក់ទងនឹងការចំណាយលើបន្សុំកាន់តែខ្ពស់។

៥. បណ្តាភាគីទទួលស្គាល់ថា សកម្មភាពបន្សុំ គួរតែធ្វើទៅតាមអភិក្រមដែលមានតម្លាភាពពេញលេញ មានការចូលរួម គិតគូរពីយេនឌ័រ និងស្របតាមកម្មវិធីរបស់ប្រទេស ដោយពិចារណាផងដែរនូវក្រុមងាយរងគ្រោះ សហគមន៍ និងប្រព័ន្ធអេកូឡូស៊ី ហើយគួរតែផ្អែកលើវិទ្យាសាស្ត្រថ្មីៗបំផុត និងប្រព័ន្ធចំណេះដឹងមូលដ្ឋាន ចំណេះដឹងប្រពៃណី ព្រមទាំងចំណេះដឹងរបស់ជនជាតិដើមទៅតាមករណីសមស្រប ក្នុងបំណងរួមបញ្ចូលបន្សុំទៅក្នុងគោលនយោបាយ និងសកម្មភាពសេដ្ឋកិច្ចសង្គម និងបរិស្ថានដែលពាក់ព័ន្ធទៅតាមករណីសមស្រប។

៦. បណ្តាភាគី ទទួលស្គាល់សារៈសំខាន់នៃកិច្ចគាំទ្រ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ លើការប្រឹងប្រែងបន្សុំ និងទទួលស្គាល់សារៈសំខាន់នៃការគិតគូរអំពីតម្រូវការរបស់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេស បណ្តាភាគីដែលងាយរងគ្រោះទៅនឹងផលប៉ះពាល់ធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ។

៧. បណ្តាភាគីគួរពង្រឹងកិច្ចសហប្រតិបត្តិការរបស់ខ្លួនក្នុងការពង្រីកសកម្មភាពបន្សុំ ដោយគិតគូរផងដែរនូវក្របខណ្ឌបន្សុំទីក្រុងកាន់គុន រួមទាំងប្រការនានាដែលជាប់ទាក់ទងនឹង៖

   (ក) ការចែករំលែកព័ត៌មាន ការអនុវត្តល្អ បទពិសោធន៍ និងមេរៀននានា ដែលមាននៅតាមករណីសមស្រប ទាក់ទងនឹងវិទ្យាសាស្ត្រ ការរៀបចំផែនការ គោលនយោបាយ និងការអនុវត្តដែលពាក់ព័ន្ធនឹងសកម្មភាពបន្សុំ។

   (ខ) ការពង្រឹងការចាត់ចែងស្ថាប័ន រួមទាំងការចាត់ចែងនានានៅក្រោមអនុសញ្ញានេះ ដែលបម្រើឱ្យផលប្រយោជន៍នៃកិច្ចព្រមព្រៀងនេះ ដើម្បីគាំទ្រដល់ការសំយោគព័ត៌មាន និងចំណេះដឹងពាក់ព័ន្ធ ព្រមទាំងផ្តល់នូវការគាំទ្របច្ចេកទេស និងសេចក្តីណែនាំដល់បណ្តាភាគី។

   (គ) ការពង្រឹងចំណេះដឹងវិទ្យាសាស្ត្រអំពីអាកាសធាតុ រួមទាំងការស្រាវជ្រាវ ការសង្កេតជាប្រព័ន្ធនៃប្រព័ន្ធអាកាសធាតុ និងប្រព័ន្ធ-ប្រកាសអាសន្នជាមុន តាមរបៀបផ្តល់ព័ត៌មានសេវាកម្មអាកាសធាតុ និងគាំទ្រដល់ការធ្វើសេចក្តីសម្រេច។

   (ឃ) ការជួយបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការកំណត់អត្តសញ្ញាណការអនុវត្តបន្សុំដែលមានប្រសិទ្ធភាព តម្រូវការបន្សុំ អាទិភាពនានា ការគាំទ្រដែលបានផ្តល់និងទទួលសម្រាប់សកម្មភាពបន្សុំនិងកិច្ចខិតខំប្រឹងប្រែងនានា ព្រមទាំងបញ្ហាប្រឈម និងចំណុចខ្វះចន្លោះ តាមទម្រង់ដែលមានសង្គតិភាពជាមួយនឹងការលើកទឹកចិត្តការអនុវត្តល្អ និង

   (ង) ការបង្កើនប្រសិទ្ធភាព និងអត្ថិភាពនៃសកម្មភាពបន្សុំ។

៨. ទីភ្នាក់ងារ និងអង្គការឯកទេសរបស់សហប្រជាជាតិ ត្រូវបានលើកទឹកចិត្ត ដើម្បីផ្តល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់បណ្តាភាគីក្នុងការអនុវត្តសកម្មភាព ដោយយោងតាមកថាខណ្ឌ ៧ នៃមាត្រានេះ ដោយគិតគូរផងដែរនូវប្រការនានាក្នុងកថាខណ្ឌ ៥ នៃមាត្រានេះ។

៩. ភាគីនីមួយៗត្រូវចូលរួមទៅតាមករណីសមស្របនៅក្នុងដំណើរការរៀបចំផែនការបន្សាំ និងការអនុវត្តសកម្មភាពដែលរួមទាំង ការរៀបចំ ឬការពង្រឹងគោលនយោបាយ ផែនការពាក់ព័ន្ធនិង/ឬការរួមចំណែក ដែលអាចរួមបញ្ចូលៈ

(ក) ការអនុវត្តសកម្មភាពបន្សាំ កិច្ចការ និង/ឬ កិច្ចខិតខំប្រឹងប្រែង

(ខ) ដំណើរការចងក្រង និងអនុវត្តផែនការជាតិបន្សាំ

(គ) ការវាយតម្លៃផលប៉ះពាល់និងភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ក្នុងបំណងកំណត់សកម្មភាពអាទិភាពដែលបានប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិ ដោយគិតគូរផងដែរពីប្រជាជន ទីកន្លែង និងប្រព័ន្ធអេកូឡូស៊ីដែលងាយរងគ្រោះ

(ឃ) ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ និងការរៀនសូត្រពីផែនការបន្សាំ គោលនយោបាយ កម្មវិធី និងសកម្មភាពនិង

(ង) ការកសាងភាពធន់នៃប្រព័ន្ធអេកូឡូស៊ី និងសេដ្ឋកិច្ចសង្គម ដែលរួមទាំង តាមរយៈពិពិធកម្មសេដ្ឋកិច្ច និងការគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តរភាព។

១០. ភាគីនីមួយៗគួរដាក់ជូន និងការធ្វើបច្ចុប្បន្នកម្មទៀងទាត់នូវរបាយការណ៍បន្សាំទៅតាមករណីសមស្រប ដែលអាចរួមបញ្ចូលអាទិភាពរបស់ខ្លួន ការអនុវត្ត និងតម្រូវការគាំទ្រ ផែនការនិងសកម្មភាព ដោយមិនបង្កើតបន្ទុកបន្ថែមណាមួយសម្រាប់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ឡើយ។

១១. របាយការណ៍បន្សាំដូចមានយោងក្នុងកថាខណ្ឌ ១០ នៃមាត្រានេះ ត្រូវដាក់ជូន និងធ្វើបច្ចុប្បន្នកម្មទៀងទាត់ទៅតាមករណីសមស្រប ដែលជាផ្នែកមួយនៃ/ឬភ្ជាប់ជាមួយរបាយការណ៍ ឬឯកសារដទៃទៀត រួមទាំងផែនការជាតិបន្សាំ ការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិ ដូចយោងតាមមាត្រា៤ កថាខណ្ឌ២ និង/ឬរបាយការណ៍ជាតិ។

១២. របាយការណ៍បន្សាំដូចមានយោងទៅក្នុងកថាខណ្ឌ ១០ នៃមាត្រានេះ ត្រូវតែកត់ត្រាក្នុងបញ្ជីសាធារណៈដែលរក្សាទុកដោយលេខាធិការដ្ឋាន។

១៣. ការបន្តនិងការពង្រឹងកិច្ចគាំទ្រអន្តរជាតិ ត្រូវតែផ្តល់ឱ្យបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ សម្រាប់ការអនុវត្តកថាខណ្ឌ ៧, ៩, ១០ និង១១ នៃមាត្រានេះ អនុលោមតាមប្រការនានានៃមាត្រា ៩, ១០, និង ១១។

១៤. របាយការណ៍សំយោគជាសាកល ដូចមានយោងក្នុងមាត្រា ១៤ ក្នុងចំណោមបញ្ហាទាំងនោះ ត្រូវតែៈ

(ក) ទទួលស្គាល់កិច្ចខិតខំប្រឹងប្រែងបន្សាំរបស់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍

(ខ) ពង្រឹងការអនុវត្តសកម្មភាពបន្សាំ ដោយគិតគូរផងដែរអំពីរបាយការណ៍បន្សាំ យោងក្នុងកថាខណ្ឌ ១០ នៃមាត្រា នេះ។

(គ) ពិនិត្យភាពគ្រប់គ្រាន់ និងប្រសិទ្ធផលនៃបន្សាំ និងការគាំទ្រដែលបានផ្តល់សម្រាប់បន្សាំ និង

(ឃ) ពិនិត្យវឌ្ឍនភាពជារួមដែលបានធ្វើឡើងនៅក្នុងការសម្រេចគោលបំណងជាសកលស្តីពីបន្សាំ ដូចមានយោងក្នុងកថាខណ្ឌ១ នៃមាត្រានេះ។

## មាត្រា៨

១. បណ្តាភាគី ទទួលស្គាល់ពីសារៈសំខាន់នៃការបញ្ចៀស ការបន្ថយជាអតិបរិមា និងការឆ្លើយតបបញ្ហា នៃការខូចខាតនិងការបាត់បង់ ពាក់ព័ន្ធជាមួយផលប៉ះពាល់ធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ រួមទាំង ព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី និងព្រឹត្តិការណ៍ដែលវិវត្តន៍យឺតៗ ព្រមទាំងតួនាទីនៃការអភិវឌ្ឍដោយចីរភាពនៅក្នុងការកាត់បន្ថយហានិភ័យនៃការខូចខាត និងការបាត់បង់។

២. យន្តការអន្តរជាតិទីក្រុងវ៉ាសូវីសម្រាប់ការខូចខាត និងការបាត់បង់ ដែលពាក់ព័ន្ធនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ច និងសេចក្តីណែនាំរបស់សន្និសីទបណ្តាភាគីដែលមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ និងអាចពង្រឹង និងពង្រីកបន្ថែមទៀត តាមការសម្រេចដោយសន្និសីទបណ្តាភាគី ដែលមាននាទីជាកិច្ចប្រជុំរបស់ភាគីក្នុងកិច្ចព្រមព្រៀងនេះ។

៣. បណ្តាភាគីគួរបង្កើនការយល់ដឹង សកម្មភាព និងការគាំទ្រ រួមទាំងតាមរយៈយន្តការអន្តរជាតិទីក្រុងវ៉ាសូវី ទៅតាមករណីសមស្រប

ដោយផ្អែកលើកិច្ចសហប្រតិបត្តិការ និងការជួយសម្រួល នៅក្នុងក្របខណ្ឌនៃការខូចខាត និងការបាត់បង់ ដែលពាក់ព័ន្ធនឹងផលប៉ះពាល់ធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ។

៤. ក្នុងន័យនេះ វិស័យនានានៃកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួល ដើម្បីបង្កើនការយល់ដឹង សកម្មភាព និងការគាំទ្រ អាចមាន៖
   (ក) ប្រព័ន្ធប្រកាសអាសន្នជាមុន
   (ខ) ការត្រៀមបង្ការសង្គ្រោះបន្ទាន់
   (គ) ព្រឹត្តិការណ៍ដែលវិវត្តន៍យឺតៗ
   (ឃ) ព្រឹត្តិការណ៍ដែលអាចពាក់ព័ន្ធនឹងការខូចខាត និងបាត់បង់ដែលមិនអាចត្រឡប់ក្រោយ និងជាអចិន្ត្រៃយ៍
   (ង) ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យគ្រប់ជ្រុងជ្រោយ
   (ច) មូលនិធិធានារ៉ាប់រងហានិភ័យ ការប្រមូលផ្តុំហានិភ័យអាកាសធាតុ និងដំណោះស្រាយផ្សេងទៀតនៃការធានារ៉ាប់រង
   (ឆ) ការបាត់បង់មិនមែនសេដ្ឋកិច្ច និង
   (ជ) ភាពធន់របស់សហគមន៍ ជីវភាពរស់នៅ និងប្រព័ន្ធអេកូឡូស៊ី។

៥. យន្តការអន្តរជាតិទីក្រុងវ៉ាសូវី ត្រូវសហការជាមួយអង្គភាព និងក្រុមជំនាញការដែលមានស្រាប់នៅក្រោមកិច្ចព្រមព្រៀងនេះ ក៏ដូចជា អង្គការ និងអង្គភាពជំនាញពាក់ព័ន្ធដែលមិននៅក្រោមកិច្ចព្រមព្រៀងនេះ។

## មាត្រា៩

១. បណ្តាភាគីប្រទេសអភិវឌ្ឍន៍ ត្រូវផ្តល់ធនធានហិរញ្ញវត្ថុ ដើម្បីជួយបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ចំពោះការកាត់បន្ថយ និងបន្សុាំ ក្នុងការបន្តកាតព្វកិច្ចដែលមានស្រាប់របស់បណ្តាភាគីនៅក្រោមអនុសញ្ញានេះ។

២. បណ្តាភាគីដទៃទៀត ត្រូវបានលើកទឹកចិត្ត ដើម្បីផ្តល់ ឬបន្តផ្តល់ការគាំទ្របែបនេះដោយស្ម័គ្រចិត្ត។

៣. ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងជសកល បណ្តាភាគីប្រទេសអភិវឌ្ឍន៍ គួរបន្តនាំមុខក្នុងការកៀរគរហិរញ្ញវត្ថុអាកាសធាតុពីប្រភព បរិធាន និងមធ្យោបាយផ្សេងៗ ដោយកត់សម្គាល់ពីតួនាទីដ៏សំខាន់នៃមូលនិធិសាធារណៈ តាមរយៈសកម្មភាពផ្សេងៗ រួមទាំងការគាំទ្រយុទ្ធសាស្ត្រស្របតាមប្រទេស និងការគិតគូរពីតម្រូវការ និងអាទិភាពរបស់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍។ ការកៀរគរហិរញ្ញវត្ថុអាកាសធាតុបែបនេះ គួរបង្ហាញពីភាពរីកចម្រើនដែលលើសពីកិច្ចខិតខំប្រឹងប្រែងកន្លងមក។

៤. ការផ្តល់ធនធានហិរញ្ញវត្ថុទ្រង់ទ្រាយធំជាងមុន គួរតែសំដៅសម្រេចឱ្យបានតុល្យភាពមួយ រវាងការកាត់បន្ថយនិងបន្សុាំ ដោយគិតគូរពីយុទ្ធសាស្ត្រ និងអាទិភាពរបស់ប្រទេស ព្រមទាំងតម្រូវការរបស់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសបណ្តាភាគីដែលងាយរងគ្រោះបំផុតពីផលប៉ះពាល់ធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ និងជួបឧបសគ្គច្រើនខាងសមត្ថភាពដូចជា បណ្តាប្រទេសអភិវឌ្ឍន៍តិចតួច និងរដ្ឋកូនកោះកំពុងអភិវឌ្ឍន៍ ដោយពិចារណាពីតម្រូវការធនធានសាធារណៈ និងជំនួយឥតសំណងសម្រាប់បន្សុាំ។

៥. បណ្តាភាគីប្រទេសអភិវឌ្ឍន៍ ត្រូវរាយការណ៍រាល់ពីរឆ្នាំម្តងនូវព័ត៌មានដែលចង្អុលបង្ហាញជាលក្ខណៈបរិមាណវិស័យ និងគុណវិស័យ ដែលទាក់ទងនឹងកថាខណ្ឌ១ និង៣ នៃមាត្រានេះ ទៅតាមករណីដែលអាចធ្វើបាន ប្រសិនបើមាន រួមទាំងនៅកម្រិតចំណោលអំពីធនធានហិរញ្ញវត្ថុសាធារណៈ ដែលត្រូវផ្តល់ទៅឱ្យបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍។ ភាគីដទៃទៀតដែលផ្តល់ធនធាន ត្រូវបានលើកទឹកចិត្តឱ្យរាយការណ៍ព័ត៌មានរាល់ពីរឆ្នាំម្តងតាមការស្ម័គ្រចិត្ត។

៦. របាយការណ៍សំយោគជាសកល ដូចមានយោងក្នុងមាត្រា១៤ គួរតែបានគិតគូរអំពីព័ត៌មានពាក់ព័ន្ធ ដែលបានផ្តល់ដោយបណ្តា ភាគីប្រទេសអភិវឌ្ឍន៍ និង/ឬ អង្គភាពនៅក្រោមកិច្ចព្រមព្រៀងនេះ អំពីកិច្ចខិតខំប្រឹងប្រែងដែលទាក់ទងនឹងហិរញ្ញវត្ថុអាកាសធាតុ។

៧. បណ្តាភាគីប្រទេសអភិវឌ្ឍន៍ ត្រូវផ្តល់ព័ត៌មានប្រកបដោយតម្លាភាពនិងសង្គតិភាពរាល់ពីរឆ្នាំម្តង អំពីការគាំទ្រសម្រាប់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ដែលបានកៀរគរនិងបានផ្តល់ តាមរយៈអន្តរាគមន៍ក្នុងវិស័យសាធារណៈ ស្របតាមបែបបទ នីតិវិធី និងគោលការណ៍ណែនាំ ដែលត្រូវអនុម័តដោយសន្និសីទបណ្តាភាគីដែលមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ នាសម័យប្រជុំលើកទីមួយរបស់ខ្លួន ដូចមានកំណត់នៅក្នុងមាត្រា ១៣ កថាខណ្ឌ១៣។ បណ្តាភាគីដទៃទៀត ត្រូវបានលើកទឹកចិត្តឱ្យធ្វើបែបនេះផងដែរ។

៨. យន្តការហិរញ្ញវត្ថុនៃអនុសញ្ញានេះ រួមទាំង អង្គភាពប្រតិបត្តិការរបស់យន្តការនេះ ត្រូវបំពេញនាទីជាយន្តការហិរញ្ញវត្ថុនៃកិច្ចព្រមព្រៀងនេះ។

៩. ស្ថាប័ននានាដែលគាំទ្រដល់ដំណើរការនៃកិច្ចព្រមព្រៀងនេះ រួមទាំង អង្គភាពប្រតិបត្តិការក្នុងយន្តការហិរញ្ញវត្ថុនៃអនុសញ្ញានេះ ត្រូវបានាប្រសិទ្ធភាពនៃការទទួលបានធនធានហិរញ្ញវត្ថុ តាមរយៈនីតិវិធីអនុម័តសាមញ្ញៗ និងការគាំទ្របន្ថែមទៀតដល់ការត្រៀម លក្ខណៈសម្រាប់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេស សម្រាប់បណ្តាភាគីប្រទេសអភិវឌ្ឍន៍តិចតួច និងបណ្តារដ្ឋកូន កោះកំពុងអភិវឌ្ឍន៍ នៅក្នុងបរិបទនៃយុទ្ធសាស្ត្រ និងផែនការអាកាសធាតុថ្នាក់ជាតិរបស់ខ្លួន។

## មាត្រា១០

១. បណ្តាភាគី ចែករំលែកចក្ខុវិស័យរយៈពេលវែងអំពីសារៈសំខាន់នៃការសម្រេចបានពេញលេញនូវការផ្ទេរ និងការអភិវឌ្ឍបច្ចេកវិទ្យា ដើម្បីកែលម្អភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

២. ដោយកត់សម្គាល់អំពីសារៈសំខាន់នៃបច្ចេកវិទ្យាសម្រាប់ការអនុវត្តសកម្មភាពកាត់បន្ថយ និងបន្សាំនៅក្រោមកិច្ចព្រមព្រៀងនេះ និង ការទទួលស្គាល់ពីការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាដែលមានស្រាប់ និងកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយ បណ្តាភាគីត្រូវពង្រឹង សកម្មភាពសហប្រតិបត្តិការលើការផ្ទេរ និងការអភិវឌ្ឍបច្ចេកវិទ្យា។

៣. យន្តការបច្ចេកវិទ្យាបង្កើតឡើងនៅក្រោមអនុសញ្ញានេះ ត្រូវគាំទ្រដល់កិច្ចព្រមព្រៀងនេះ។

៤. ក្របខណ្ឌបច្ចេកវិទ្យាមួយត្រូវបានបង្កើតឡើង ដើម្បីផ្តល់សេចក្តីណែនាំសំខាន់ដល់ការងារនៃយន្តការបច្ចេកវិទ្យា សំដៅលើក កម្ពស់ និងសម្រួលដល់ការពង្រឹងសកម្មភាពពីការផ្ទេរ និងការអភិវឌ្ឍបច្ចេកវិទ្យា ដើម្បីគាំទ្រដល់ការអនុវត្តកិច្ចព្រមព្រៀងនេះ ឈានទៅរកការសម្រេចចក្ខុវិស័យរយៈពេលវែងដូចមានយោងក្នុងកថាខណ្ឌ១ នៃមាត្រានេះ។

៥. ការបង្កើនល្បឿន ការលើកទឹកចិត្ត និងការបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់នវានុវត្តន៍ មានសារៈសំខាន់ណាស់ក្នុងការឆ្លើយ តបទៅនឹងការប្រែប្រួលអាកាសធាតុជាសកលរយៈពេលវែង និងប្រកបដោយប្រសិទ្ធភាព និង ព្រមទាំងការលើកកម្ពស់កំណើន សេដ្ឋកិច្ច និងការអភិវឌ្ឍដោយចីរភាព។ កិច្ចខិតខំប្រឹងប្រែងបែបនេះ ត្រូវទទួលបានការគាំទ្រ ទៅតាមករណីសមស្រប ដោយរួម បញ្ចូលទាំង យន្តការបច្ចេកវិទ្យា និង យន្តការហិរញ្ញវត្ថុនៃអនុសញ្ញានេះតាមរយៈមធ្យោបាយហិរញ្ញវត្ថុ សម្រាប់អភិក្រមតាមបែប កិច្ចសហការក្នុងការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងបង្កលក្ខណៈងាយស្រួលក្នុងការទទួលបានបច្ចេកវិទ្យា ជាពិសេសក្នុងដំណាក់ កាលដំបូងៗនៃវដ្តបច្ចេកវិទ្យាទៅដល់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍។

៦. ការគាំទ្រ ដែលរួមបញ្ចូលទាំងការគាំទ្រហិរញ្ញវត្ថុ ត្រូវតែបានផ្តល់ឱ្យបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍សម្រាប់អនុវត្តមាត្រានេះ ដែលរួមទាំងសម្រាប់ពង្រឹងសកម្មភាពសហប្រតិបត្តិការលើការផ្ទេរ និងការអភិវឌ្ឍបច្ចេកវិទ្យានៅដំណាក់កាលខុសៗគ្នានៃវដ្ត បច្ចេកវិទ្យា ក្នុងបំណងសម្រេចបាននូវតុល្យភាពរវាងការគាំទ្រដល់ការកាត់បន្ថយ និងបន្សាំ។ របាយការណ៍សំយោគជា សកល ដូចមានយោងក្នុងមាត្រា ១៤ ត្រូវគិតគូរអំពីព័ត៌មានដែលមានស្តីពីកិច្ចខិតខំប្រឹងប្រែងដែលទាក់ទងនឹងការគាំទ្រដល់ការ ផ្ទេរ និងការអភិវឌ្ឍបច្ចេកវិទ្យាសម្រាប់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍។

## មាត្រា១១

១. ការកសាងសមត្ថភាពនៅក្រោមកិច្ចព្រមព្រៀងនេះ គួរតែជួយពង្រឹងសមត្ថភាព និងលទ្ធភាពនៃបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេស បណ្តាប្រទេសដែលមានសមត្ថភាពតិចតួច ដូចជា ប្រទេសអភិវឌ្ឍន៍តិចតួច និងប្រទេសដែលងាយរងគ្រោះជាពិសេស នៅចំពោះមុខផលប៉ះពាល់ធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ ដូចជា បណ្តារដ្ឋកូនកោះកំពុងអភិវឌ្ឍន៍ ដើម្បីចាត់វិធានការ ប្រកបដោយប្រសិទ្ធភាពក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ រួមទាំង ក្នុងចំណោមបញ្ហាទាំងនោះមានដូចជា ការអនុ វត្តសម្មភាពបន្សាំនិងកាត់បន្ថយ ហើយគួរសម្រួលឱ្យមានការអភិវឌ្ឍ ការផ្សព្វផ្សាយ និងការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យា ការទទួល បានហិរញ្ញវត្ថុអាកាសធាតុ ទិដ្ឋភាពពាក់ព័ន្ធនានានៃការអប់រំ ការបណ្តុះបណ្តាល និងការយល់ដឹងជាសាធារណៈ និងការរាយ ការណ៍ព័ត៌មានដោយតម្លាភាព ទាន់ពេលវេលា និងសុក្រិត។

២. ការកសាងសមត្ថភាព គួរធ្វើឡើងស្របតាមកម្មវិធីរបស់ប្រទេស ផ្អែកលើនិងឆ្លើយតបនឹងតម្រូវជាតិ និងជំរុញភាពជាម្ចាស់របស់ ប្រទេសនៃបណ្តាភាគី ជាពិសេសបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ រួមទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន។ ការកសាងសមត្ថភាព គួរតែធ្វើតាមមេរៀនជាបទពិសោធដែលទទួលបាន រួមទាំង មេរៀនចេញពីសកម្មភាពកសាងសមត្ថភាព នៅក្រោមអនុសញ្ញានេះ និងគួរតែជាដំណើរការធ្វើឡើងជាប្រចាំ និងប្រកបដោយប្រសិទ្ធភាព ដែលមានការចូលរួម មានលក្ខណៈ

អន្តរវិស័យ និងឆ្លើយតបទៅនឹងយេនឌ័រ។

៣. បណ្តាភាគីទាំងអស់គួរសហប្រតិបត្តិការដើម្បីពង្រឹងសមត្ថភាពរបស់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។ បណ្តាភាគីប្រទេសអភិវឌ្ឍន៍ គួរពង្រឹងការគាំទ្រដល់សកម្មភាពកសាងសមត្ថភាពនៅក្នុងបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍។

៤. បណ្តាភាគីទាំងអស់ដែលពង្រឹងសមត្ថភាពនៃបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ រួមទាំង តាមរយៈអភិក្រមពហុភាគី ទ្វេភាគី និងតំបន់ ត្រូវរាយការណ៍ជាទៀងទាត់អំពីសកម្មភាព ឬ វិធានការទាំងនេះ លើការកសាងសមត្ថភាព។ បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ គួររាយការណ៍ជាទៀងទាត់អំពីវឌ្ឍនភាពដែលសម្រេចបានលើការអនុវត្ត វិធានការ សកម្មភាព គោលនយោបាយ ឬផែនការកសាងសមត្ថភាព ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។

៥. សកម្មភាពកសាងសមត្ថភាពត្រូវតែបានពង្រឹង តាមរយៈ ការចាត់ចែងស្ថាប័នឱ្យសមស្រប ដើម្បីគាំទ្រការអនុវត្តកិច្ចព្រមព្រៀងនេះ រួមទាំង ការចាត់ចែងស្ថាប័នឱ្យសមស្រប ដែលបានបង្កើតឡើងនៅក្រោមអនុសញ្ញានេះ ដែលគាំទ្រដល់ កិច្ចព្រមព្រៀងនេះ។ នៅក្នុងសម័យប្រជុំលើកទីមួយរបស់ខ្លួន សន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវតែពិចារណា និងអនុម័តសេចក្តីសម្រេចមួយស្តីការចាត់ចែងស្ថាប័នដំបូងសម្រាប់ការកសាងសមត្ថភាព។

## មាត្រា១២

បណ្តាភាគីត្រូវសហប្រតិបត្តិការ ក្នុងការចាត់វិធានការ ទៅតាមករណីសមស្រប ដើម្បីពង្រឹងការអប់រំ ការបណ្តុះបណ្តាល ការយល់ដឹងជាសាធារណៈ ការចូលរួមជាសាធារណៈ និងការទទួលបានព័ត៌មានជាសាធារណៈ អំពីការប្រែប្រួលអាកាសធាតុ ដោយទទួលស្គាល់ពីសារៈសំខាន់នៃជំហានទាំងនេះ ដែលទាក់ទងនឹងការពង្រឹងសកម្មភាពនៅក្រោមកិច្ចព្រមព្រៀងនេះ។

## មាត្រា១៣

១. ដើម្បីកសាងទំនុកចិត្តនិងការជឿជាក់គ្នាទៅវិញទៅមក និងដើម្បីលើកកម្ពស់ការអនុវត្តប្រកបដោយប្រសិទ្ធផល ក្របខណ្ឌពង្រឹងតម្លាភាពសម្រាប់សកម្មភាពនិងការគាំទ្រ គួបផ្សំជាមួយភាពបត់បែនបាន ដែលគិតគូរអំពីសមត្ថភាពខុសៗគ្នារបស់បណ្តាភាគី និងកសាងបន្ថែមលើបទពិសោធន៍រួម ត្រូវបានបង្កើតឡើង។

២. ក្របខណ្ឌតម្លាភាព ត្រូវផ្តល់ភាពបត់បែននៅក្នុងការអនុវត្តប្រការនានានៃមាត្រានេះ ដល់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ដែលត្រូវការសមត្ថភាពបែបនេះ ដោយពិចារណាផងដែរអំពីសមត្ថភាព របស់បណ្តាភាគីទាំងនោះ។ បែបបទ នីតិវិធី និងគោលការណ៍ណែនាំដូចមានយោងក្នុង កថាខណ្ឌ១៣ នៃមាត្រានេះ ត្រូវឆ្លុះបញ្ចាំងពីភាពបត់បែនបាននេះ។

៣. ក្របខណ្ឌតម្លាភាព ត្រូវកសាងបន្ថែមលើ និងពង្រឹងការរៀបចំតម្លាភាព នៅក្រោមអនុសញ្ញានេះ ដោយទទួលស្គាល់នូវកាលៈទេសៈជាពិសេសរបស់បណ្តាប្រទេសអភិវឌ្ឍន៍តិចតួច និងរដ្ឋកូនកោះកំពុងអភិវឌ្ឍន៍ និងត្រូវអនុវត្តក្របខណ្ឌនេះតាមវិធី ដែលមានលក្ខណៈជួយសម្រួល គ្មានការរំលោភសិទ្ធិ គ្មានការដាក់ទណ្ឌកម្ម មានការគោរពអធិបតេយ្យជាតិ និងបញ្ចៀសការបង្កបន្ទុកមិនចាំបាច់មកលើបណ្តាភាគី។

៤. ការរៀបចំតម្លាភាពនៅក្រោមអនុសញ្ញានេះ ដែលរួមទាំង របាយការណ៍ជាតិ របាយការណ៍ប្រចាំពីរឆ្នាំម្តង និងរបាយការណ៍បច្ចុប្បន្នភាពប្រចាំពីរឆ្នាំម្តង ការពិនិត្យនិងវាយតម្លៃជាអន្តរជាតិ ព្រមទាំងការពិគ្រោះយោបល់និងការវិភាគជាអន្តរជាតិ ត្រូវចងក្រងជាផ្នែកនៃបទពិសោធន៍ដែលបានដកស្រង់ សម្រាប់ការរៀបចំទម្រង់បែបបទ នីតិវិធី និងគោលការណ៍ណែនាំនៅក្រោម កថាខណ្ឌ១៣ នៃមាត្រានេះ។

៥. គោលបំណងនៃក្របខណ្ឌសម្រាប់តម្លាភាពនៃសកម្មភាព គឺដើម្បីផ្តល់ការយល់ដឹងច្បាស់លាស់អំពីសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដោយគិតគូរផងដែរពីគោលដៅនៃអនុសញ្ញានេះ ដូចមានចែងនៅក្នុងមាត្រា២ រួមទាំង ភាពច្បាស់លាស់ និងការតាមដានវឌ្ឍនភាពឆ្ពោះទៅសម្រេចបាននូវការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិរបស់បណ្តាភាគី នៅក្រោមមាត្រា៤ ហើយសកម្មភាពបន្សាំរបស់បណ្តាភាគី នៅក្រោមមាត្រា៧ រួមទាំង ការអនុវត្តល្អ អាទិភាព តម្រូវការ និងភាពខ្វះចន្លោះ ដើម្បីរាយការណ៍ពីរបាយការណ៍សំយោគជាសកលនៅក្រោមមាត្រា១៤។

៦. គោលបំណងនៃក្របខណ្ឌសម្រាប់តម្លាភាពនៃការគាំទ្រ គឺដើម្បីផ្តល់ភាពច្បាស់លាស់លើការគាំទ្រដែលបានផ្តល់និងបានទទួលដោយបណ្តាភាគីពាក់ព័ន្ធនីមួយៗ នៅក្នុងបរិបទនៃសកម្មភាពប្រែប្រួលអាកាសធាតុ នៅក្រោមមាត្រា៤, ៧, ៩, ១០ និង ១១ និង

ដើម្បីផ្តល់ទិដ្ឋភាពរួមពេញលេញមួយ ទៅតាមកម្រិតអាចធ្វើបាន នៃការគាំទ្រហិរញ្ញវត្ថុសរុបដែលបានផ្តល់ ដើម្បីរបាយការណ៍ពីរបាយការណ៍សំយោគជាសកលនៅក្រោមមាត្រា១៤។

៧. ភាគីនីមួយៗត្រូវផ្តល់ជាទៀងទាត់នូវព័ត៌មានខាងក្រោម៖

(ក) របាយការណ៍សារពើភ័ណ្ឌជាតិអំពីការបញ្ចេញឧស្ម័នដោយសកម្មភាពមនុស្សគិតតាមប្រភពបញ្ចេញនិងការស្រូបឧស្ម័នដោយអាងស្រូបឧស្ម័នផ្ទះកញ្ចក់ ដែលរៀបចំឡើងដោយប្រើប្រាស់វិធីសាស្ត្រអនុវត្តន៍ល្អ ដែលទទួលយកដោយក្រុមការងារអន្តររដ្ឋាភិបាលប្រែប្រួលអាកាសធាតុនិងឯកភាពពីសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

(ខ) ព័ត៌មានចាំបាច់ដើម្បីតាមដានវឌ្ឍនភាពដែលសម្រេចបាននៅក្នុងការអនុវត្ត និងលទ្ធផលក្នុងការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិ នៅក្រោមមាត្រា៤។

៨. ភាគីនីមួយៗក៏គួរផ្តល់ព័ត៌មានទាក់ទងនឹងបន្ស៊ាំនិងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្រោមមាត្រា៧ទៅតាមករណីសមស្រប។

៩. បណ្តាភាគីប្រទេសអភិវឌ្ឍន៍ត្រូវ ហើយបណ្តាភាគីដទៃទៀតដែលផ្តល់ការគាំទ្រក៏គួរ ផ្តល់ព័ត៌មានអំពីការគាំទ្រផ្នែកហិរញ្ញវត្ថុ ការផ្ទេរបច្ចេកវិទ្យា និងការកសាងសមត្ថភាព ដែលបានផ្តល់ឱ្យបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍នៅក្រោមមាត្រា៩, ១០ និង ១១។

១០. បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍គួរផ្តល់ព័ត៌មានអំពីតម្រូវការ និងការទទួលបាននូវការគាំទ្រផ្នែកហិរញ្ញវត្ថុ ការផ្ទេរបច្ចេកវិទ្យា និងការកសាងសមត្ថភាពនៅក្រោមមាត្រា៩, ១០ និង ១១។

១១. ព័ត៌មានដែលភាគីនីមួយៗបានដាក់ជូននៅក្រោមកថាខណ្ឌ៧និង៩ នៃមាត្រានេះ ត្រូវពិនិត្យដោយអ្នកជំនាញការបច្ចេកទេសអនុលោមតាមសេចក្តីសម្រេច 1/CP.21។ ចំពោះបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ដែលត្រូវការព័ត៌មាននេះ ដោយគិតពិចារណាពីសមត្ថភាពរបស់ខ្លួន ដំណើរការពិនិត្យត្រូវរួមបញ្ចូលជំនួយក្នុងការកំណត់តម្រូវការកសាងសមត្ថភាព។ លើសពីនេះ ភាគីនីមួយៗ ត្រូវចូលរួមការអនុវត្តនិងការសម្រេចបានលើការចូលរួមចំណែកប្តេជ្ញាអនុវត្តថ្នាក់ជាតិរៀងៗខ្លួន តាមបែបសម្របសម្រួល និងការគិតគូរបែបលក្ខណៈពហុភាគីអំពីវឌ្ឍនភាពដោយគោរពតាមកិច្ចខិតខំប្រឹងប្រែងនៅក្រោមមាត្រា៩។

១២. ការពិនិត្យរបស់អ្នកជំនាញបច្ចេកទេសនៅក្រោមកថាខណ្ឌនេះ ត្រូវរួមមានការពិចារណារបស់ភាគីដែលមានការគាំទ្រទៅតាមករណីពាក់ព័ន្ធនិងការអនុវត្តព្រមទាំងការសម្រេចបានលើការចូលរួមចំណែកប្តេជ្ញាអនុវត្តថ្នាក់ជាតិរបស់ភាគីនោះ។ ការពិនិត្យ ក៏ត្រូវកំណត់ពីវិស័យនានាសម្រាប់កែលម្អរបស់ភាគី និងរួមបញ្ចូលទាំងការពិនិត្យលើសង្គតិភាពនៃព័ត៌មានជាមួយបែបបទ នីតិវិធី និងគោលការណ៍ណែនាំ ដូចមានយោងនៅក្នុងកថាខណ្ឌ១៣ នៃមាត្រានេះ ដោយគិតគូរអំពីភាពបត់បែនដែលបានព្រមព្រៀងឱ្យទៅភាគីនៅក្រោមកថាខណ្ឌ២នៃមាត្រានេះ។ ការពិនិត្យនេះត្រូវផ្តោតការយកចិត្តទុកដាក់ជាពិសេសលើសមត្ថភាពនិងកាលៈទេសៈរបស់ជាតិនៃបណ្តាភាគី ប្រទេសកំពុងអភិវឌ្ឍន៍។

១៣. នាសម័យប្រជុំលើកទីមួយរបស់ខ្លួន ដោយបន្ថែមលើបទពិសោធន៍ចេញពីការចាត់ចែងដែលទាក់ទងនឹងតម្លាភាព នៅក្រោមអនុសញ្ញានេះ និងពន្យល់ពិស្តារអំពីប្រការនានានៅក្រោមមាត្រានេះ សន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះត្រូវអនុម័តបែបបទ នីតិវិធី និងគោលការណ៍ណែនាំរួម ទៅតាមករណីសមស្រប សម្រាប់តម្លាភាពនៃសកម្មភាព និងការគាំទ្រ។

១៤. ការគាំទ្រត្រូវផ្តល់ទៅឱ្យបណ្តាប្រទេសកំពុងអភិវឌ្ឍន៍សម្រាប់ការអនុវត្តមាត្រានេះ។

១៥. ការគាំទ្រត្រូវផ្តល់ជាបន្តបន្ទាប់ទៅឱ្យបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ សម្រាប់ការកសាងសមត្ថភាពដែលទាក់ទងនឹងតម្លាភាព។

## មាត្រា១៤

១. សន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវធ្វើរបាយការណ៍សំយោគទៀងទាត់អំពីការអនុវត្តកិច្ចព្រមព្រៀងនេះ ដើម្បីវាយតម្លៃវឌ្ឍនភាពរួមគ្នា ក្នុងការឈានទៅសម្រេចបំណងនៃកិច្ចព្រមព្រៀងនេះ និងគោលបំណងរយៈពេលវែង (ដែលហៅថា "របាយការណ៍សំយោគជាសកល")។ សន្និសីទត្រូវរៀបចំឱ្យបានទូលំទូលាយ និងតាមរបៀបសម្របសម្រួលផងដែរដោយពិចារណាអំពីការកាត់បន្ថយ បន្ស៊ាំ និងមធ្យោបាយនៃការអនុវត្ត និងគាំទ្រ ហើយក្នុងបរិបទសមធម៌ និងវិទ្យាសាស្ត្រសមស្របបំផុតដែលមាន។

២. សន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវរៀបចំរបាយការណ៍សំយោគជាសកលលើក

ទី១របស់ខ្លួននៅឆ្នាំ២០២៣ និងបន្ទាប់ពីនោះ រៀងរាល់ប្រាំឆ្នាំម្តង លើកលែងតែមានការសម្រេចផ្ទុយពីនេះដោយសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

៣. លទ្ធផលនៃរបាយការណ៍សំយោគជាសកល ត្រូវជូនដំណឹងដល់បណ្តាភាគីក្នុងការធ្វើបច្ចុប្បន្នកម្ម និងការពង្រឹងសកម្មភាពនិងការគាំទ្ររបស់ខ្លួនតាមបែបការប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិ ស្របតាមប្រការនានានៃកិច្ចព្រមព្រៀងនេះ ក៏ដូចជាក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់សកម្មភាពអាកាសធាតុ ។

## មាត្រា១៥

១. យន្តការមួយដើម្បីសម្រួលឱ្យមានការអនុវត្ត និងលើកកម្ពស់អនុលោមភាពតាមប្រការនានានៃកិច្ចព្រមព្រៀងនេះ ត្រូវបានបង្កើតឡើងចាប់ពីនេះទៅ។

២. យន្តការដូចមានយោងក្នុងកថាខណ្ឌ១ នៃមាត្រានេះ ត្រូវមានគណៈកម្មការមួយដែលមានមុខងារ និងចរិតលក្ខណៈជាអ្នកជំនាញ និងជួយសម្រួលយន្តការនេះ ប្រកបដោយតម្លាភាព មិនវាយប្រហារនិងមិនដាក់ទណ្ឌកម្មទៅភាគីណាមួយឡើយ។ គណៈកម្មការនេះត្រូវផ្តោតការយកចិត្តទុកដាក់ជាពិសេសលើកាលៈទេសៈនិងសមត្ថភាពជាតិ របស់បណ្តាភាគី។

៣. គណៈកម្មការនេះត្រូវប្រតិបត្តិការទៅតាមបែបបទ និងនីតិវិធីដែលអនុម័តដោយសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ នាសម័យប្រជុំលើកទី១របស់ខ្លួន និងរាយការណ៍ប្រចាំឆ្នាំទៅសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

## មាត្រា១៦

១. សន្និសីទបណ្តាភាគីដែលជាអង្គកំពូលនៃអនុសញ្ញានេះ ត្រូវមាននាទីជាកិច្ចប្រជុំបណ្តាភាគីនៅក្នុងកិច្ចព្រមព្រៀងនេះ។

២. បណ្តាភាគីក្នុងអនុសញ្ញា ដែលមិនមែនជាភាគីក្នុងកិច្ចព្រមព្រៀងនេះ អាចចូលរួមជាអ្នកសង្កេតការណ៍នៅក្នុងដំណើរការប្រព្រឹត្តទៅនៃសម័យប្រជុំនៃសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។ នៅពេលសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ការសម្រេចនានាដែលនៅក្រោមកិច្ចព្រមព្រៀង ត្រូវធ្វើឡើងដោយបណ្តាភាគីនៅក្នុងកិច្ចព្រមព្រៀងនេះតែប៉ុណ្ណោះ។

៣. នៅពេលសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ សមាជិកណាមួយនៃការិយាល័យសន្និសីទបណ្តាភាគី ដែលតំណាងឱ្យភាគីមួយនៅក្នុងអនុសញ្ញានេះ ប៉ុន្តែពេលនោះមិនមែនជាភាគីមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវជំនួសដោយសមាជិកបន្ថែមដែលត្រូវបានបោះឆ្នោតដោយ និងចេញពីក្នុងចំណោមបណ្តាភាគីនៅក្នុងកិច្ចព្រមព្រៀងនេះ។

៤. សន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវធ្វើការពិនិត្យជាទៀងទាត់នូវការអនុវត្តកិច្ចព្រមព្រៀងនេះ និងត្រូវធ្វើសេចក្តីសម្រេចចាំបាច់នៅក្នុងអាណត្តិរបស់ខ្លួនដើម្បីជំរុញការអនុវត្តកិច្ចព្រមព្រៀងនេះឱ្យមានប្រសិទ្ធភាព។ សន្និសីទបណ្តាភាគីនេះត្រូវបំពេញមុខងារដែលកំណត់ដោយកិច្ចព្រមព្រៀងនេះ និងត្រូវ៖

(ក) បង្កើតអង្គចំណុះតាមការចាំបាច់សម្រាប់អនុវត្តកិច្ចព្រមព្រៀងនេះ និង

(ខ) អនុវត្តមុខងារដទៃទៀតតាមលក្ខខណ្ឌតម្រូវសម្រាប់អនុវត្តកិច្ចព្រមព្រៀងនេះ។

៥. វិធាននៃនីតិវិធីនៅក្នុងសន្និសីទបណ្តាភាគី និងនៅក្នុងនីតិវិធីហិរញ្ញវត្ថុ ដែលបានអនុវត្តនៅក្រោមអនុសញ្ញានេះ ក៏ត្រូវយកមកអនុវត្តនៅក្រោមកិច្ចព្រមព្រៀងនេះផងដែរ ដោយមានការកែសម្រួលខ្លះៗតាមការចាំបាច់ លើកលែងតែមានការសម្រេចជាឯកច្ឆន្ទផ្សេងទៀតដោយសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

៦. សម័យប្រជុំលើកទីមួយនៃសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ នឹងត្រូវបានកោះប្រជុំដោយលេខាធិការដ្ឋាន ដោយភ្ជាប់ជាមួយសម័យប្រជុំលើកទីមួយនៃសន្និសីទបណ្តាភាគីដែលគ្រោងធ្វើឡើងនៅក្រោយកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។ សម័យប្រជុំសាមញ្ញជាបន្តបន្ទាប់នៃសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ នឹងត្រូវធ្វើឡើងព្រមពេលជាមួយគ្នានឹងសម័យប្រជុំសាមញ្ញនៃសន្និសីទបណ្តាភាគី លើកលែងតែមានការសម្រេចផ្ទុយពីនេះដោយសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

៧. សម័យប្រជុំវិសាមញ្ញនៃសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវធ្វើឡើងនៅក្នុងពេលណា

មួយផ្សេង តាមការចាំបាច់ដោយសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ឬ តាមការស្នើសុំជាលាយលក្ខណ៍អក្សរដោយភាគីណាមួយ នៅក្នុងករណីដែលមានការគាំទ្រយ៉ាងតិចមួយភាគបីនៃចំនួនភាគីទាំងអស់ នៅក្នុងកំលុងពេលប្រាំមួយខែក្រោយការជូនដំណឹងដោយលេខាធិការដ្ឋានអំពីការស្នើសុំនេះ។

៨. អង្គការសហប្រជាជាតិ និងទីភ្នាក់ងារឯកទេសរបស់ខ្លួន និងទីភ្នាក់ងារថាមពលអាតូមិកអន្តរជាតិ ក៏ដូចជា រដ្ឋសមាជិកណាមួយនៃអង្គការឬទីភ្នាក់ងារ ឬអ្នកសង្កេតការណ៍ ដែលមិនមែនជាភាគីនៅក្នុងអនុសញ្ញានេះ អាចមានតំណាងនៅក្នុងសម័យប្រជុំនានានៃសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ក្នុងនាមជាអ្នកសង្កេតការណ៍។ អង្គភាព ឬទីភ្នាក់ងារណាមួយ ទោះជាថ្នាក់ជាតិ ឬអន្តរជាតិ រដ្ឋាភិបាល ឬមិនមែនរដ្ឋាភិបាល ដែលមានសមត្ថភាពលើកិច្ចការដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះ ហើយដែលបានជូនដំណឹងមកលេខាធិការដ្ឋានអំពីបំណងក្នុងការបញ្ជូនតំណាងរបស់ខ្លួនចូលរួមក្នុងសម័យប្រជុំណាមួយនៃសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ក្នុងនាមជាអ្នកសង្កេតការណ៍ អាចបានទទួលការអនុញ្ញាតឱ្យបញ្ជូនតំណាងដើម្បីចូលរួម លុះត្រាតែមានការជំទាស់យ៉ាងតិចមួយភាគបីនៃចំនួនភាគីទាំងអស់ក្នុងកិច្ចព្រមព្រៀងនេះ។ ការអនុញ្ញាត និងការចូលរួមរបស់អ្នកសង្កេតការណ៍ ត្រូវធ្វើឡើងតាមវិធាននៃនីតិវិធីដូចមានយោងក្នុងកថាខណ្ឌ៥ នៃមាត្រានេះ។

## មាត្រា១៧

១. លេខាធិការដ្ឋានដែលបង្កើតឡើងតាមមាត្រា៨ នៃអនុសញ្ញានេះ ត្រូវដើរតួជាលេខាធិការដ្ឋាននៃកិច្ចព្រមព្រៀងនេះ។

២. មាត្រា៨ កថាខណ្ឌ២ នៃអនុសញ្ញានេះ អំពីមុខងាររបស់លេខាធិការដ្ឋាន ហើយមាត្រា៨ កថាខណ្ឌ៣ នៃអនុសញ្ញានេះ អំពីការរៀបចំចាត់ចែងសម្រាប់មុខងាររបស់លេខាធិការដ្ឋាន ត្រូវយកមកអនុវត្ត ដោយមានការកែសម្រួលខ្លះៗតាមការចាំបាច់នៅក្នុងកិច្ចព្រមព្រៀងនេះ។ លើសពីនេះ លេខាធិការដ្ឋាននេះត្រូវអនុវត្តមុខងារនានាដែលបានកំណត់នៅក្រោមកិច្ចព្រមព្រៀងនេះ និងដោយសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

## មាត្រា១៨

១. អង្គចំណុះសម្រាប់ប្រឹក្សាយោបល់ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអង្គចំណុះសម្រាប់អនុវត្តន៍ ដែលបានបង្កើតឡើងតាមមាត្រា៩ និង១០នៃអនុសញ្ញាត្រូវមាននាទីជាអង្គចំណុះសម្រាប់ប្រឹក្សាយោបល់ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអង្គចំណុះសម្រាប់អនុវត្តន៍នៃកិច្ចព្រមព្រៀងនេះ។ ប្រការនានានៃអនុសញ្ញានេះ ដែលទាក់ទងនឹងមុខងាររបស់អង្គចំណុះទាំងពីរនេះ ត្រូវតែយកមកអនុវត្តសម្រាប់កិច្ចព្រមព្រៀងនេះ ដោយមានការកែសម្រួលខ្លះៗតាមការចាំបាច់។ សម័យប្រជុំនៃអង្គចំណុះសម្រាប់ប្រឹក្សាយោបល់ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអង្គចំណុះសម្រាប់អនុវត្តន៍កិច្ចព្រមព្រៀងនេះ ត្រូវធ្វើឡើងជាមួយគ្នានឹងកិច្ចប្រជុំនៃអង្គចំណុះសម្រាប់ផ្តល់យោបល់ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអង្គចំណុះសម្រាប់អនុវត្តន៍នៃអនុសញ្ញានេះ។

២. បណ្តាភាគីក្នុងអនុសញ្ញាដែលមិនមែនជាបណ្តាភាគីនៅក្នុងកិច្ចព្រមព្រៀងនេះ អាចចូលរួមជាអ្នកសង្កេតការណ៍នៅក្នុងដំណើរការប្រព្រឹត្តទៅនៃសម័យប្រជុំណាមួយរបស់អង្គចំណុះ។ នៅពេលដែលអង្គចំណុះទាំងនេះ ដើរតួជាអង្គចំណុះនៃកិច្ចព្រមព្រៀងនេះ សេចក្តីសម្រេចនានានៅក្រោមកិច្ចព្រមព្រៀងនេះ នឹងត្រូវធ្វើឡើងដោយបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះតែប៉ុណ្ណោះ។

៣. នៅពេលដែលអង្គចំណុះនានាដែលបានបង្កើតឡើងតាមមាត្រា៩ និង១០ នៃអនុសញ្ញានេះ អនុវត្តមុខងាររបស់ខ្លួនទាក់ទងជាមួយកិច្ចការនានាពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងនេះ សមាជិកណាមួយក្នុងការិយាល័យរបស់អង្គចំណុះដែលតំណាងឱ្យភាគីណាមួយនៅក្នុងអនុសញ្ញានេះ ប៉ុន្តែនៅពេលនោះពុំមែនជាភាគីនៃកិច្ចព្រមព្រៀងនេះ ត្រូវតែជំនួសដោយសមាជិកបន្ថែមដែលនឹងត្រូវជ្រើសរើសដោយនិងក្នុងចំណោមបណ្តាភាគីនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា១៩

១. អង្គចំណុះ ឬការចាត់ចែងស្ថាប័នដទៃទៀត បានបង្កើតឡើងដោយឬនៅក្រោមអនុសញ្ញានេះ ក្រៅពីនោះត្រូវយោងទៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបម្រើនាទីក្នុងកិច្ចព្រមព្រៀងនេះ ទៅតាមសេចក្តីសម្រេចដោយសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។ សន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវគូសបញ្ជាក់ពីមុខងារនានា

ដែលត្រូវអនុវត្តដោយអង្គចំណុះឬការចាត់ចែងបែបនេះ។

២. សន្និសីទបណ្ដាភាគីមាននាទីជាកិច្ចប្រជុំបណ្ដាភាគីក្នុងកិច្ចព្រមព្រៀងនេះ អាចផ្ដល់សេចក្ដីណែនាំបន្ថែមដល់អង្គចំណុះនិងការចាត់ចែងបែបនេះ។

## មាត្រា២០

១. កិច្ចព្រមព្រៀងនេះនឹងត្រូវបើកចំហរសម្រាប់ការចុះហត្ថលេខា និងផ្ដល់សច្ចាប័ន ការទទួលយក ឬ ការអនុម័តដោយរដ្ឋនានា និង អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដែលជាភាគីក្នុងអនុសញ្ញានេះ។ កិច្ចព្រមព្រៀងនេះនឹងត្រូវបើកចំហរសម្រាប់ការចុះហត្ថលេខានៅស្នាក់ការកណ្ដាលនៃអង្គការសហប្រជាជាតិនាទីក្រុងញូវយ៉ក ចាប់ពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ ដល់ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៧។ ចាប់ពីពេលនោះតទៅ កិច្ចព្រមព្រៀងនេះនឹងត្រូវបើកចំហរសម្រាប់ការសុំចូលរួមជាភាគី គិតចាប់ពីកាលបរិច្ឆេទ ដែលបិទបញ្ចប់សម្រាប់ការចុះហត្ថលេខា។ លិខិតូបករណ៍នៃការផ្ដល់សច្ចាប័ន ការទទួលយក ការអនុម័ត ឬការសុំចូលរួមជាភាគី នឹងត្រូវរក្សាទុកនៅក្នុងកន្លែងតំកល់ឯកសារ។

២. អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ណាមួយដែលក្លាយជាភាគីមួយក្នុងកិច្ចព្រមព្រៀងនេះ ដោយគ្មានរដ្ឋសមាជិកណាមួយរបស់ខ្លួនជាភាគីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវតែមានភារៈកិច្ចអនុវត្តគ្រប់កាតព្វកិច្ចនៅក្រោមកិច្ចព្រមព្រៀងនេះ។ នៅក្នុងករណីដែលអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដែលមានរដ្ឋជាសមាជិកមួយឬច្រើន ដែលជាភាគីនៅក្នុងកិច្ចព្រមព្រៀងនេះ អង្គការនោះនិងរដ្ឋសមាជិករបស់ខ្លួន ត្រូវធ្វើសេចក្ដីសម្រេចអំពីការទទួលខុសត្រូវរៀងៗខ្លួនសម្រាប់ការបំពេលកាតព្វកិច្ចនៅក្រោមកិច្ចព្រមព្រៀងនេះ។ នៅក្នុងករណីបែបនេះ អង្គការនោះនិងរដ្ឋជាសមាជិករបស់ខ្លួន មិនត្រូវទទួលបានសិទ្ធិអនុវត្តន៍នានានៅក្រោមកិច្ចព្រមព្រៀងនេះ នៅក្នុងពេលទន្ទឹមគ្នា។

៣. នៅក្នុងលិខិតូបករណ៍នៃការផ្ដល់សច្ចាប័ន ការទទួលយក ការអនុម័ត ឬការចូលរួមជាភាគី អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ត្រូវប្រកាសវិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួន ដែលទាក់ទងនឹងកិច្ចការនានាមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ។ អង្គការទាំងនេះត្រូវជូនដំណឹងដល់កន្លែងតំកល់ឯកសារ ដែលត្រូវជូនដំណឹងជាបន្តទៅភាគីនានា អំពីការកែប្រែជាទ្រង់ទ្រាយធំណាមួយ ចំពោះវិសាលភាពនៃសមត្ថកិច្ចរបស់ពួកគេ។

## មាត្រា ២១

១. កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាននៅក្នុងរយៈពេលសាមសិបថ្ងៃក្រោយកាលបរិច្ឆេទ ដែលយ៉ាងតិចមានភាគីចំនួន៥៥ នៃអនុសញ្ញានេះ ដែលគិតជាបរិមាណសរុប យ៉ាងតិចប្រមាណ៥៥ ភាគរយនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបលើពិភពលោក បានដាក់តំកល់លិខិតូបករណ៍របស់ខ្លួននៃការផ្ដល់សច្ចាប័ន ការទទួលយក ការអនុម័ត ឬ ការចូលរួមជាភាគី។

២. សម្រាប់គោលបំណងដែលបានកំណត់តែមួយគត់ដូចក្នុងកថាខណ្ឌ១ នៃមាត្រានេះ "ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបលើពិភពលោក" មានន័យថាជាបរិមាណឧស្ម័នថ្មីបំផុតដែលមាននៅក្នុងរបាយការណ៍ ឬមុនកាលបរិច្ឆេទនៃការអនុម័តកិច្ចព្រមព្រៀងនេះដោយបណ្ដាភាគីក្នុងអនុសញ្ញានេះ។

៣. សម្រាប់រដ្ឋនីមួយៗ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ដែលផ្ដល់សច្ចាប័ន ទទួលយក ឬអនុម័តកិច្ចព្រមព្រៀងនេះ ឬចូលរួមជាភាគីបន្ទាប់ពីបានបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌ១នៃមាត្រានេះកិច្ចព្រមព្រៀងនេះនឹងចូលជាធរមាន នៅក្នុងរយៈពេលសាមសិបថ្ងៃក្រោយកាលបរិច្ឆេទនៃការដាក់តំកល់លិខិតូបករណ៍របស់ខ្លួននៃការផ្ដល់សច្ចាប័ន ការទទួលយក ការអនុម័ត ឬ ការចូលរួមជាភាគី ដោយរដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់។

៤. សម្រាប់បំណងនៃកថាខណ្ឌ១ នៃមាត្រានេះ លិខិតូបករណ៍ណាមួយដែលបានតំកល់ទុកដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ មិនត្រូវបានរាប់បញ្ចូលបន្ថែមទៅលើលិខិតូបករណ៍ដែលបានតំកល់ដោយរដ្ឋជាសមាជិករបស់ខ្លួនឡើយ។

## មាត្រា២២

ប្រការនានាក្នុងមាត្រា១៥ នៃអនុសញ្ញាស្ដីពីការអនុម័តលើវិសោធនកម្មអនុសញ្ញានេះ ត្រូវយកមកអនុវត្តដោយមានការកែសម្រួលខ្លះៗតាមភាពចាំបាច់ចំពោះកិច្ចព្រមព្រៀងនេះ។

## មាត្រា២៣

១. ប្រការនានាក្នុងមាត្រា១៦ នៃអនុសញ្ញាស្តីពីការអនុម័ត និងវិសោធនកម្មឧបសម្ព័ន្ធនានានៃអនុសញ្ញានេះ ត្រូវយកមកអនុវត្តដោយមានការកែសម្រួលខ្លះៗតាមការចាំបាច់ចំពោះកិច្ចព្រមព្រៀងនេះ ។

២. ឧបសម្ព័ន្ធនានានៃកិច្ចព្រមព្រៀងនេះ ត្រូវតែជាទម្រង់ផ្នែកសំខាន់មួយ និងលើកលែងតែមានការចែងផ្ទុយពីនេះ សេចក្តីយោងនៃកិច្ចព្រមព្រៀងនេះក៏ជាសេចក្តីយោងទៅនឹងឧបសម្ព័ន្ធណាមួយផងដែរ។ ឧបសម្ព័ន្ធបែបនេះត្រូវរៀបចំជាបញ្ជី ជាទម្រង់ឯកសារ និងសម្ភារៈដទៃទៀតដែលមានលក្ខណៈពិពណ៌នាតាមបែប វិទ្យាសាស្ត្រ បច្ចេកទេស នីតិវិធី ឬរដ្ឋបាល។

## មាត្រា២៤

ប្រការនានាក្នុងមាត្រា១៤ នៃអនុសញ្ញាស្តីពីការដោះស្រាយទំនាស់ ត្រូវយកមកអនុវត្តដោយមានការកែសម្រួលតាមការចាំបាច់ចំពោះកិច្ចព្រមព្រៀងនេះ។

## មាត្រា២៥

១. ភាគីនីមួយៗត្រូវមានសម្លេងមួយនៅក្នុងការបោះឆ្នោត លើកលែងតែករណីដូចមានចែងក្នុងកថាខណ្ឌ២ នៃមាត្រានេះ។

២. នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ត្រូវអនុវត្តសិទ្ធិរបស់ខ្លួនដើម្បីបោះឆ្នោតដោយមានសម្លេងឆ្នោតស្មើទៅនឹងចំនួនបណ្តារដ្ឋជាសមាជិកជាភាគីក្នុងកិច្ចព្រមព្រៀងនេះ។ អង្គការ នោះមិនត្រូវអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការបោះឆ្នោតឡើយ ផ្ទុយមកវិញ ប្រសិនបើរដ្ឋជាសមាជិករបស់ខ្លួនអនុវត្តសិទ្ធិ ក្នុងការបោះឆ្នោត។

## មាត្រា២៦

អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ត្រូវតែជាអ្នកតំកល់ទុកកិច្ចព្រមព្រៀងនេះ។

## មាត្រា២៧

គ្មានសេចក្តីបម្រុងណាមួយអាចត្រូវបានធ្វើឡើងសម្រាប់កិច្ចព្រមព្រៀងនេះ។

## មាត្រា២៨

១. ក្រោយរយៈពេលបីឆ្នាំក្នុងពេលណាមួយគិតចាប់ពីកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះបានចូលជាធរមានសម្រាប់ភាគីមួយ ភាគីនោះអាចដកខ្លួនចេញពីកិច្ចព្រមព្រៀងនេះដោយជូនដំណឹងជាលាយលក្ខណ៍អក្សរមកកន្លែងតំកល់ឯកសារ។

២. រាល់ការដកខ្លួនណាមួយ ត្រូវមានប្រសិទ្ធភាពក្នុងរយៈពេលមួយឆ្នាំនៃការផុតកំណត់ដោយគិតចាប់ពីកាលបរិច្ឆេទ ដែលកន្លែងតំកល់ឯកសារបានទទួលសេចក្តីជូនដំណឹងអំពីការដកខ្លួនចេញនេះ ឬនៅកាលបរិច្ឆេទណាមួយក្រោយមក តាមការបញ្ជាក់ក្នុងសេចក្តីជូនដំណឹងអំពីការដកខ្លួនចេញនោះ។

៣. បណ្តាភាគីណាមួយដែលដកខ្លួនចេញពីអនុសញ្ញានេះ ត្រូវបានចាត់ទុកថាបានដកខ្លួនចេញពីកិច្ចព្រមព្រៀងនេះផងដែរ។

## មាត្រា២៩

ច្បាប់ដើមនៃកិច្ចព្រមព្រៀងនេះ ដែលមានអត្ថបទជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ មានតម្លៃប្រើប្រាស់ត្រឹមត្រូវដូចគ្នា ត្រូវដាក់តំកល់ទុកដោយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ។

ធ្វើនៅក្រុងប៉ារីស ថ្ងៃទីដប់ពីរ ខែធ្នូ ឆ្នាំពីរពាន់ដប់ប្រាំ។
ដើម្បីជាសាក្សី អ្នកទទួលសិទ្ធិប្រទាន ដើម្បីចុះហត្ថលេខា បានចុះហត្ថលេខាដើម្បីផ្តល់សុពលភាពលើកិច្ចព្រមព្រៀងនេះ។

---